**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១១០ អនក្រ.បក**

**អនុក្រឹត្យ**

**ស្តីពី**

**ការកាត់ឆ្វៀលដីទំហំ ៥៨,៨៤ ហិកតា ចេញពីតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិព្រះមុនីវង្ស(បូកគោ)កំណត់តាមអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១ កំណត់ជាតំបន់សហគមន៍ និងផ្តល់កម្មសិទ្ធិជូនប្រជាពលរដ្ឋ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ ._**

កាត់ឆ្វៀលដីទំហំ ៥៨,៨៤ ហិកតា ចេញពីតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិព្រះមុនីវង្ស (បូកគោ) កំណត់តាមអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១ កំណត់ជាតំបន់សហគមន៍ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទី បង្ហាញទីតាំងដី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២ ._**

ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលសរុបចំនួន ២៤ ក្បាលដី ជូនប្រជាពលរដ្ឋ ២២ គ្រួសារ នៅឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត ក្នុងនោះ ចំនួន ២៣ ក្បាលដី ជូនប្រជាពលរដ្ឋ ២១ គ្រួសារ នៅភូមិគីឡូ១២ និងក្បាលដីចំនួន ០១ ក្បាលដី ជូនប្រជាពលរដ្ឋ ០១ គ្រួសារ នៅភូមិព្រែកចេក។

**មាត្រា៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៥ ៣៨ ខែ បឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ២០២១ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីនិងតារាងនិយាមការឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.១១០អនក.បក.ចុះថ្ងៃទី....៩.......ខែ..កក្កដា....ឆ្នាំ២០២១




កាវាងនិយាមការព្រំដី

Projection UTM Zone 48N, Datum WGS 1984

| ID | E | N | ID | E | N | ID | E | N |
|---|---|---|---|---|---|---|---|---|
| 1 | 399206 | 1169704 | 59 | 399334 | 1169794 | 117 | 400414 | 1169586 |
| 2 | 399187 | 1169777 | 60 | 399322 | 1169796 | 118 | 400400 | 1169813 |
| 3 | 399177 | 1169868 | 61 | 399318 | 1169817 | 119 | 400416 | 1169647 |
| 4 | 399173 | 1169871 | 62 | 399286 | 1169852 | 120 | 400409 | 1169866 |
| 5 | 399199 | 1169989 | 63 | 399251 | 1169966 | 121 | 400416 | 1169728 |
| 6 | 399211 | 1169984 | 64 | 399243 | [illegible] | 122 | [illegible] | 1169749 |
| 7 | 399239 | 1169875 | 65 | 399720 | 1170187 | 123 | 400470 | 1169727 |
| 8 | 399236 | 1169873 | 66 | 399720 | 1170132 | 124 | 400479 | 1169734 |
| 9 | 399269 | 1169791 | 67 | 399163 | 1170271 | 125 | 400492 | 1169751 |
| 10 | 399311 | 1169715 | 68 | 399572 | 1169731 | 126 | 400505 | 1169761 |
| 11 | 399260 | 1169710 | 69 | 399517 | 1169674 | 127 | 400536 | 1169774 |
| 12 | 399074 | 1170484 | 70 | 399545 | 1169670 | 128 | 400580 | 1169754 |
| 13 | 399118 | 1170481 | 71 | 399542 | 1169630 | 129 | 400548 | 1169708 |
| 14 | 399216 | 1170476 | 72 | 399533 | 1169584 | 130 | 400527 | 1169658 |
| 15 | 399223 | 1170476 | 73 | 399588 | 1169578 | 131 | 400494 | 1169630 |
| 16 | 399251 | 1170411 | 74 | 399844 | 1169325 | 132 | 400483 | 1169548 |
| 17 | 399251 | 1170410 | 75 | 399923 | 1169306 | 133 | 400482 | 1169544 |
| 18 | 399253 | 1170409 | 76 | 399891 | 1169013 | 134 | 400502 | 1169535 |
| 19 | 399418 | 1170333 | 77 | 399840 | 1169022 | 135 | 400536 | 1169523 |
| 20 | 399418 | 1170332 | 78 | 399813 | 1169026 | 136 | 400483 | 1169384 |
| 21 | 399419 | 1170332 | 79 | 400235 | 1168861 | 137 | 400519 | 1169373 |
| 22 | 399420 | 1170332 | 80 | 400273 | 1168859 | 138 | 400517 | 1169363 |
| 23 | 399420 | 1170332 | 81 | 400265 | 1168819 | 139 | 400508 | 1169351 |
| 24 | 399545 | 1170338 | 82 | 400232 | 1168788 | 140 | 400489 | 1169309 |
| 25 | 399635 | 1170263 | 83 | 400187 | 1168774 | 141 | 400483 | 1169270 |
| 26 | 399638 | 1170260 | 84 | 400161 | 1168804 | 142 | 400483 | 1169268 |
| 27 | 399635 | 1170199 | 85 | 400150 | 1168813 | 143 | 400478 | 1169212 |
| 28 | 399635 | 1170198 | 86 | 400134 | 1168824 | 144 | 400467 | 1169131 |
| 29 | 399615 | 1170107 | 87 | 400101 | 1168851 | 145 | 400460 | 1169126 |
| 30 | 399615 | 1170107 | 88 | 400085 | 1168888 | 146 | 400458 | 1169124 |
| 31 | 399615 | 1170106 | 89 | 400075 | 1168941 | 147 | 400404 | 1169062 |
| 32 | 399624 | 1170012 | 90 | 400068 | 1168972 | 148 | 400404 | 1169061 |
| 33 | 399628 | 1169916 | 91 | 400144 | 1168982 | 149 | 400390 | 1169036 |
| 34 | 399626 | 1169824 | 92 | 400162 | 1169059 | 150 | 400384 | 1169024 |
| 35 | 399625 | 1169729 | 93 | 400184 | 1169054 | 151 | 400380 | 1169014 |
| 36 | 399622 | 1169578 | 94 | 400187 | 1169078 | 152 | 400373 | 1168988 |
| 37 | 399617 | 1169577 | 95 | 400196 | 1169116 | 153 | 400376 | 1168987 |
| 38 | 399596 | 1169568 | 96 | 400233 | 1169087 | 154 | 400364 | 1168951 |
| 39 | 399585 | 1169519 | 97 | 400257 | 1169138 | 155 | 400352 | 1168916 |
| 40 | 399568 | 1169390 | 98 | 400294 | 1169175 | 156 | 400339 | 1168886 |
| 41 | 399555 | 1169339 | 99 | 400311 | 1169132 | 157 | 400326 | 1168874 |
| 42 | 399537 | 1169215 | 100 | 400324 | 1169144 | 158 | 400240 | 1168898 |
| 43 | 399529 | 1169092 | 101 | 400326 | 1169166 | 159 | 400225 | 1168859 |
| 44 | 399393 | 1169104 | 102 | 400283 | 1169182 | 160 | 400201 | 1168863 |
| 45 | 399386 | 1169122 | 103 | 400270 | 1169197 | 161 | 400193 | 1168881 |
| 46 | 399380 | 1169121 | 104 | 400307 | 1169249 | 162 | 400170 | 1168885 |
| 47 | 399367 | 1169236 | 105 | 400349 | 1169236 | 163 | 400160 | 1168945 |
| 48 | 399336 | 1169365 | 106 | 400357 | 1169268 | 164 | 400145 | 1168945 |
| 49 | 399336 | 1169424 | 107 | 400393 | 1169316 | 165 | 400367 | 1169088 |
| 50 | 399332 | 1169493 | 108 | 400351 | 1169339 | 166 | 400338 | 1169036 |
| 51 | 399299 | 1169554 | 109 | 400343 | 1169354 | 167 | 400398 | 1169222 |
| 52 | 399296 | 1169588 | 110 | 400323 | 1169376 | 168 | 400381 | 1169152 |
| 53 | 399372 | 1169565 | 111 | 400288 | 1169385 | 169 | 400438 | 1169296 |
| 54 | 399388 | 1169572 | 112 | 400298 | 1169430 | 170 | 400482 | 1169536 |
| 55 | 399391 | 1169597 | 113 | 400371 | 1169484 | 171 | 400252 | 1169177 |
| 56 | 399405 | 1169640 | 114 | 400428 | 1169453 | 172 | 400289 | 1169153 |
| 57 | 399400 | 1169683 | 115 | 400455 | 1169543 | 173 | 400246 | 1169162 |
| 58 | 399362 | 1169748 | 116 | 400417 | 1169557 | | | |